

Created by Ben Davis from Noun Project

# ម្ចាស់ផ្ទះខ្ញុំបិទទឹកភ្លើងរបស់ខ្ញុំ!

## តើខ្លឹមសារនេះសម្រាប់នរណា?

អ្នកជួលផ្ទះនៅរដ្ឋ Washington ដែលម្ចាស់ផ្ទះទើបតែបានបិទទឹកភ្លើងរបស់ពួកគេព្យាយាមបង្ខំពួកគេឱ្យរើចេញ។

## តើអ្នកនឹងដឹងអ្វីខ្លះតាមរយៈការអានខ្លឹមសារនេះ?

- អ្វីដែលត្រូវធ្វើប្រសិនបើម្ចាស់ផ្ទះរបស់អ្នកបិទទឹកភ្លើងរបស់អ្នកដោយខុសច្បាប់។
- កន្លែងដែលត្រូវទៅរកជំនួយផ្លូវច្បាប់។

## តើច្បាប់ចែងពីអ្វីខ្លះ?

RCW 59.18.300 ចែងថាវាជាទង្វើខុសច្បាប់សម្រាប់ម្ចាស់ផ្ទះបិទសេវាទឹកភ្លើងដោយមានបំណង (ដោយចេតនា)។ នេះរួមបញ្ចូលទាំងទឹក ម៉ាស៊ីនកម្តៅ ភ្លើង ឬហ្គាស លើកលែងតែនេះជាការបិទបណ្តោះអាសន្ន ដើម្បីធ្វើការជួសជុលចាំបាច់។

---

❖ ច្បាប់របស់រដ្ឋ Washington ត្រូវបានគេគេហៅថា **ច្បាប់ដែលបានពិនិត្យសើរើរបស់រដ្ឋ Washington (RCW)** ។ ច្បាប់សំខាន់បំផុតដែលមានឥទ្ធិពលលើអ្នកជួល និងម្ចាស់ផ្ទះគឺស្ថិតនៅក្នុង **ច្បាប់ម្ចាស់ផ្ទះ និងអ្នកជួលផ្ទះ**(RCW 59.18)។

---

ម៉្យាងទៀត វាជាការខុសច្បាប់សម្រាប់ម្ចាស់ផ្ទះកាត់ផ្តាច់ទឹកភ្លើងរបស់អ្នក ដើម្បីព្យាយាមធ្វើឱ្យអ្នកចាកចេញពីផ្ទះជួល។

អ្នកអាចប្តឹងម្ចាស់ផ្ទះនៅពេលក្រោយមក (ជាធម្មតានៅក្នុងតុលាការបណ្តឹងសំណងតូច) ចំពោះសំណងខូចខាតផ្នែកហិរញ្ញវត្ថុដែលអ្នកបានទទួលរងដោយសារតែអ្នកត្រូវបានចាក់សោមិនឲ្យចូលផ្ទះ។ អ្នកក៏អាចប្តឹងទាមទារសំណងចំនួន 100 ដុល្លារក្នុងមួយថ្ងៃដែលអ្នកមិនមានសេវាទឹកភ្លើងផងដែរ។ ចូរអាន តើតុលាការបណ្តឹងទាមទារសំណងតូចគឺជាអ្វី? និង តើខ្ញុំប្តឹងដោយរបៀបណានៅក្នុងតុលាការបណ្តឹងទាមទារសំណងតូច?

## តើម្ចាស់ផ្ទះអាចកាត់ផ្តាច់ទឹកភ្លើងដោយស្របច្បាប់បានដែរឬទេ?

ប្រហែលជាអាចបាន។ បើកិច្ចសន្យាជួលរបស់អ្នកចែងថាអ្នកត្រូវបង់ថ្លៃសេវាទឹកភ្លើង ប៉ុន្តែអ្នកមិនបានបង់ ក្រុមហ៊ុនសេវាទឹកភ្លើងអាចកាត់ផ្តាច់ទឹកភ្លើងបាន។

បើអ្នកបាន "**បោះបង់ចោល**" ទីកន្លែង–និងបានចាកចេញពីផ្ទះជួល ហើយឈប់បង់ថ្លៃឈ្នួលដោយមិនប្រាប់ម្ចាស់ផ្ទះ – ម្ចាស់ផ្ទះអាចកាត់ផ្តាច់ទឹកភ្លើងបាន។

## តើអ្នកអាចធ្វើអ្វីខ្លះបាន ប្រសិនបើម្ចាស់ផ្ទះរបស់អ្នកបិទទឹកភ្លើង?

សូមទូរស័ព្ទប្តឹងសមត្ថកិច្ច។
អនុញ្ញាតឱ្យសមត្ថកិច្ចដឹងថាម្ចាស់ផ្ទះរបស់អ្នកបិទទឹកភ្លើងរបស់អ្នកដោយគ្មានដីការបស់ ចៅក្រម។
សមត្ថកិច្ចអាចចេញមុខ ហើយធ្វើឱ្យម្ចាស់ផ្ទះបើកទឹកភ្លើងវិញ។

បន្ទាប់មកព្យាយាមរកជំនួយផ្លូវច្បាប់។

## ទទួលជំនួយផ្នែកច្បាប់

ច្បាប់ស្តីពីការបណ្តេញចេញ និងវិធីដែលតុលាការកំពុងដោះស្រាយវិបត្តិ COVID-19 អាចផ្លាស់ប្តូរយ៉ាងឆាប់រហ័ស និងខុសគ្នាអាស្រ័យលើទីកន្លែងដែលអ្នករស់នៅ។ ទទួលបានព័ត៌មានថ្មីបំផុត
និងស្វែងយល់អំពីជំនួយសម្រាប់ការប ណ្តេញចេញនៅក្នុងតំបន់របស់អ្នកនៅលើគេហទំព័រ WashingtonLawHelp.org។

**នៅក្រៅខោនធី King**៖ សូមហៅទៅលេខទូរស័ព្ទទាន់ហេតុការណ៍ CLEAR តាមលេខ1-888-201-1014 នៅថ្ងៃធ្វើការចាប់ពីម៉ោង 9:15 ព្រឹកដល់ម៉ោង 12:15 ថ្ងៃត្រង់។

**នៅក្នុងខោនធី King**៖ ទូរស័ព្ទទៅលេខ 2-1-1 សម្រាប់ការបញ្ជូនទៅកាន់អ្នកផ្តល់សេវាផ្លូវច្បាប់នៅថ្ងៃធ្វើការចាប់ពីម៉ោង 8:00 ព្រឹកដល់ 6:00 ល្ងាច។

**មនុស្សអាយុចាប់ពី 60 ឆ្នាំឡើង** អាចទូរស័ព្ទទៅ CLEAR*Sr តាមលេខ 1-888-387-7111 (ទូទាំងរដ្ឋ)។

**មនុស្សថ្លង់ ធ្ងន់ត្រចៀក ឬអ្នកមានបញ្ហាក្នុងការនិយាយ** អាចទូរស័ព្ទទៅ CLEAR ឬលេខ 211 (ឬលេខឥតគិតថ្លៃ
1-877-211-9274) ដោយប្រើសេវាកម្មបញ្ជូនបន្តតាមជម្រើសរបស់ពួកគេ។

**ដាក់ពាក្យសុំតាមអនឡាញជាមួយ CLEAR*Online** - nwjustice.org/get-legal-help

CLEAR និង 211 នឹងផ្តល់ជូនអ្នកបកប្រែផ្ទាល់មាត់ដោយឥតគិតថ្លៃ។

---

ការបោះពុម្ពផ្សាយនេះផ្តល់នូវព័ត៌មានទូទៅទាក់ទងនឹងសិទ្ធិ និងការទទួលខុសត្រូវរបស់អ្នក។ ឯកសារនេះមិនមែនរៀបរៀងឡើងសម្រាប់ជំនួសឱ្យការប្រឹក្សាផ្លូវច្បាប់ជាក់លាក់ទេ។

**© 2020 Northwest Justice Project — 1-888-201-1014.**

(ការអនុញ្ញាតឱ្យថតចម្លង និងចែកចាយទៅឱ្យសម្ព័ន្ធភាពដើម្បីយុត្តិធម៌ស្មើភាពគ្នា និងចំពោះបុគ្គលគឺសម្រាប់តែគោលបំណងមិនមែនពាណិជ្ជកម្មប៉ុណ្ណោះ។)